ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..០០៥......សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៦

# សារាចរ

## ស្តីពី

## ការណែនាំលើការអនុវត្តន៍ថវិកាឆ្នាំ ២០០៦

I. សេចក្តីផ្តើម

១. ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ។ ដើម្បីអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១៥៣ អនក្រ.ប.ក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការផ្ទេរថវិកា អនុក្រឹត្យលេខ ១៥៤ អនក្រ.ប.ក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ និង អនុក្រឹត្យលេខ ១៥៥ អនក្រ.ប.ក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។ ដោយផ្អែកលើមូលដ្ឋាននៃអនុក្រឹត្យនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានចេញប្រកាសលេខ ៩៨៨_សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលថវិកាទូទៅរបស់រដ្ឋសំរាប់ ការគ្រប់គ្រងឆ្នាំ ២០០៥ ប្រកាសលេខ ៩៨៩ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយឥណទានថវិកាផ្ទៃក្នុងជំពូកតាមប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ និង ប្រកាសលេខ ៩៩០ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការផ្ទេរឥណទានថវិកា ។ ដើម្បីឱ្យការអនុវត្តន៍ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ មានដំណើរការប្រកបដោយលទ្ធផលល្អ និង មានប្រសិទ្ធភាពខ្ពស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំលើការអនុវត្តន៍ថវិការដ្ឋ ឆ្នាំ ២០០៦ ដែលមានតាមលំដាប់លំដោយដូចខាងក្រោម ។

២- ថវិកាឆ្នាំ ២០០៦ ត្រូវបានរៀបចំឡើងដោយផ្អែកលើកម្មវិធីគោលនយោបាយ ៧៣ ចំណុចរបស់រាជរដ្ឋាភិបាលនីតិកាលទី ៣ នៃរដ្ឋសភា ដែលសំដៅបំពីអោយការអនុវត្ត ***ផែនការយុទ្ធសាស្ត្រជាតិសំរាប់ការអភិវឌ្ឍន៍ (National Strategy Development Plan-NSDP)*** ការបន្តអនុវត្តន៍ ***យុទ្ធសាស្ត្រជាតិ***

*កាត់បន្ថយភាពក្រីក្រ (National Poverty Reduction Strategy-NPRS)* និង ជាពិសេស ការអនុវត្តន៍ *«យុទ្ធសាស្ត្រចតុកោណ» (Rectangular Strategy)*-ដើម្បី *កំណើន ការងារ សមធម៌* និង *ប្រសិទ្ធភាព* ។ ជាក់ស្តែង ថវិការដ្ឋឆ្នាំ ២០០៦ បានបង្ហាញពីឆន្ទៈនយោបាយដ៏មោះមុតក្នុងការបន្តអនុវត្តកម្មវិធីកំណែទំរង់លើគ្រប់ផ្នែករបស់រាជរដ្ឋាភិបាលដូចជា (១) ការបន្តអនុវត្តកម្មវិធីកែទំរង់ហិរញ្ញវត្ថុសាធារណៈ ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ (២) ការអនុវត្តន៍កំណែទំរង់រចនាសម្ព័ន្ធ ដើម្បីពង្រឹងបរិស្ថានអំណោយផលសម្រាប់ការអភិវឌ្ឍន៍ផ្នែកឯកជន (៣) ការអនុវត្តន៍នូវកំណែទម្រង់ការគ្រប់គ្រងដីធ្លី ដើម្បីលើកស្ទួយ និង ប្រែក្លាយវិស័យកសិកម្មអោយទៅជាមូលដ្ឋានរឹងមាំនៃកំណើនសេដ្ឋកិច្ច និង បំពីអោយគោលដៅនៃការកាត់បន្ថយភាពក្រីក្រ (៤) ការពង្រឹងប្រព័ន្ធធនាគារ និង វិស័យធានារ៉ាប់រង និង ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុទាំងមូល ដើម្បីកៀរគរធនធានហិរញ្ញវត្ថុសម្រាប់ការធ្វើហិរញ្ញប្បទានគម្រោងរបស់ផ្នែកឯកជន (៥) ការកសាង និង ពង្រឹងការអនុវត្តន៍ច្បាប់ និងបទបញ្ជា ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និង អភិបាលកិច្ចល្អ (៦) ការអនុវត្តកំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការ ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលបច្ចេកទេស និង ហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាឃុំ- សង្កាត់ និង ការអភិវឌ្ឍន៍មូលដ្ឋាន និង (៧) ការអនុវត្តន៍កំណែទម្រង់រដ្ឋបាលសាធារណៈ ពិសេស ការពង្រឹង និង ពង្រីកការអនុវត្តន៍កន្សោមអាទិភាព និង កម្មវិធីផ្តល់លាភការទៅតាមសមត្ថភាព និង លទ្ធផលការងារដើម្បីបង្កើនប្រសិទ្ធភាព និង ផលិតភាពការងារ ។

## II. ល័ក្ខខ័ណ្ឌ និង វិធានការក្នុងការអនុវត្តន៍ថវិកាឆ្នាំ ២០០៦

### ក- ការអនុវត្តន៍ការប្រមូលចំណូលថវិកា

៣. ដើម្បីអោយការអនុវត្តន៍ច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ សំរេចបានជោគជ័យ ជាពិសេស ដើម្បីអោយការអនុវត្តន៍ថវិកាសំរេចបានតាមការគ្រោងទុក ជាក់ស្តែងគឺដើម្បីអោយការប្រមូលចំណូលក្នុងស្រុកសំរេចបានតាមគោលដៅ ២ ៩០៥ ៣២០ លានរៀល គឺស្មើនឹង ១២% នៃផសស រាជរដ្ឋាភិបាលនឹងជំរុញការបង្កើនការប្រមូលចំណូលចរន្តអោយបាន ២ ៨៣៣ ៣២០ លានរៀល បើធៀបទៅនឹងចំណូលចរន្តនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ គឺនឹងត្រូវកើនឡើង ២០,៣% ដែលក្នុងនោះចំណូលសារពើពន្ធនឹងត្រូវកើន ២២,៦% (ចំណូលគយ និង រដ្ឋាករនឹងត្រូវកើន ២១,៨% និង ចំណូលពន្ធដារនឹងត្រូវកើន ២៥%) និង ចំណូលមិនមែនសារពើពន្ធនឹងត្រូវកើន ១២,៦% ។

៤- ថវិកាឆ្នាំ ២០០៦ បានឆ្លុះបញ្ចាំងពីកំនើននៃចំណូលធៀបនឹងគំរោងចំណូលថវិកាឆ្នាំ ២០០៥ ជាពិសេស ការបង្កើនចំណូលក្នុងស្រុកអោយដល់ ២ ៩០៥ ៣២០ ពាន់លានរៀល គឺស្មើនឹង ១២% (ចំណូលក្នុងស្រុកដែលជាថវិការដ្ឋ ២ ៨១២ ៧២០ ពាន់លានរៀល គឺស្មើនឹង ១១,៦២% នៃផសស) នៃផសស ដែលនឹងមានកំនើនស្មើនឹង ២៥,៩% (ចំណូលថវិការដ្ឋកើន ២៥,៩%) ធៀបទៅនឹងលទ្ធផលប៉ាន់ស្មានចំណូលថវិកាឆ្នាំ ២០០៥ ។ ការបង្កើន និង ពង្រឹងការកៀរគរចំណូលគឺជាយុទ្ធសាស្ត្រស្នូលនៃគោលនយោបាយថវិកាឆ្នាំ ២០០៦

ជាពិសេស ការផ្តោតជាសំខាន់ទៅលើការពង្រឹងរដ្ឋបាលពន្ធដារ និង រដ្ឋបាលគយ និង រដ្ឋាករ ក្នុងគោលដៅសំរេចឱ្យបាននូវចំណូលសារពើពន្ធ ២ ២០៨ ពាន់លានរៀល គឺស្មើនឹង ៩,១២% (ចំណូលសារពើពន្ធដែលជាថវិការដ្ឋគឺស្មើនឹង ៨,៨២%) នៃផសស ក្នុងឆ្នាំ ២០០៦ ដែលមានកំនើនស្មើនឹង ២៥,៣% ធៀបទៅនឹងលទ្ធផលប៉ាន់ស្មានចំណូលថវិកាឆ្នាំ ២០០៥ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងពង្រឹងការអនុវត្តន៍ឱ្យមានប្រសិទ្ធភាពនូវច្បាប់ស្តីពីសារពើពន្ធ ពង្រឹង និង ពង្រីកសមត្ថភាពស្ថាប័ន ពង្រីកមូលដ្ឋានយកពន្ធ ព្រមទាំងទប់ស្កាត់អំពើគេចពន្ធគ្រប់បែបយ៉ាង ។ ម្យ៉ាងទៀត ចំណូលមិនមែនសារពើពន្ធនឹងសំរេចអោយបាន ៦២៥,៣២០ ពាន់លានរៀល (ចំណូលមិនមែនសារពើពន្ធដែលជាថវិការដ្ឋ ៦០៥,៧២០ ពាន់លានរៀល) គឺស្មើនឹង ២,៥៨% (ចំណូលមិនមែនសារពើពន្ធដែលជាថវិការដ្ឋគឺស្មើនឹង ២,៥០%) នៃផសស បើធៀបនឹងផែនការ ឆ្នាំ ២០០៥ គឺមានការកើនឡើង ១២,៦០% (ចំណូលមិនមែនសារពើពន្ធដែលជាថវិការដ្ឋកើនឡើង ១២%) ហើយនឹងកើនឡើង ១៨,២% (ចំណូលមិនមែនសារពើពន្ធដែលជាថវិការដ្ឋនឹងកើនឡើង ១៧,៧%) បើធៀបនឹងលទ្ធផលប៉ាន់ស្មានចំណូលថវិកាឆ្នាំ ២០០៥ ។

៥- ដើម្បីសំរេចបានតាមគោលដៅខាងលើ នាយកដ្ឋានពន្ធដារ និង ទីចាត់ការគយ និង រដ្ឋាករ ត្រូវរៀបចំកម្មវិធីប្រមូលចំណូលសារពើពន្ធប្រចាំត្រីមាសដែលមានការបែងចែកលំអិតទៅតាមខែ ។ បើគិតជាមធ្យមភាគប្រចាំខែ នាយកដ្ឋានពន្ធដារមានភារកិច្ចប្រមូលចំណូលពន្ធផ្ទៃក្នុងឱ្យបានជាមធ្យមចំនួន ៤៣,៧៥ ពាន់លានរៀលក្នុងមួយខែ ។ ចំណែកទីចាត់ការគយ និង រដ្ឋាករមានភារកិច្ចប្រមូលចំណូលពន្ធអាករឱ្យបានជាមធ្យមចំនួនប្រមាណ ១៣៤,១៦ ពាន់លានរៀលក្នុងមួយខែ ទោះជាការប្រមូលជាក់ស្តែងអាចមានកំរិតខ្ពស់ ឬ ទាបជាងការគ្រោងទុកបន្តិចបន្តួចទៅតាមស្ថានភាពសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈក៏ដោយ ។ ទន្ទឹមនឹងនេះ កម្មវិធីប្រមូលចំណូលនេះត្រូវមានផែនការសកម្មភាពអនុវត្តលំអិតហើយប្រគល់ឱ្យសាខាទីស្នាក់ការ និង មន្ត្រីម្នាក់ៗ ដើម្បីទទួលខុសត្រូវដោយផ្ទាល់ទៅតាមភារកិច្ចដែលខ្លួនត្រូវបំពេញរៀងៗខ្លួន ។

៦- ដើម្បីសំរេចបាននូវការប្រមូលចំណូលមិនមែនសារពើពន្ធឆ្នាំ ២០០៦ ចំនួន ៦២៥,៣២០ ពាន់លានរៀល ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរបស់ខ្លួននៅតាមខេត្ត-ក្រុងត្រូវរៀបចំកម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំត្រីមាស ដែលមានការបែងចែកលំអិតតាមខែ ដោយផ្អែកលើកិច្ចសន្យានៃការជួលទ្រព្យសម្បត្តិរដ្ឋ កិច្ចសន្យាសម្បទាននានា ចំណូលពីសេវាបង់ថ្លៃសកម្មភាពអាជីវកម្ម និង សង្វាក់នៃការប្រមូលចំណូលកន្លងមក ។ ក្រសួង-ស្ថាប័នត្រូវប្រគល់ការអនុវត្តន៍កម្មវិធីនេះ ទៅឱ្យអង្គភាពក្រោមឱវាទនៅរដ្ឋបាលកណ្តាល និងនៅខេត្ត-ក្រុង អោយទទួលខុសត្រូវដោយផ្ទាល់ចំពោះការប្រមូលចំណូលទាំងនោះ ។ អង្គភាពប្រមូលចំណូល ត្រូវធ្វើការតាមដាន និង ជំរុញជាប្រចាំនូវការអនុវត្តន៍កម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំត្រីមាស និង រិះរកវិធានការទាន់ពេលវេលាក្នុងករណីចាំបាច់ ។

៧- ទន្ទឹមនឹងនេះ ដើម្បីអោយការអនុវត្តន៍កម្មវិធីប្រមូលចំណូលប្រចាំត្រីមាសសំរេចបានប្រកបដោយប្រសិទ្ធភាពខ្ពស់ អង្គភាពនីមួយៗ ត្រូវធ្វើការតាមដាន និង ត្រួតពិនិត្យជាប្រចាំ (ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំខែ និង ប្រចាំត្រីមាស) លើលទ្ធផលដែលសំរេចបាន ដើម្បីរកវិធានការទាន់ពេលវេលាក្នុងករណីចាំបាច់ ។ ក្រៅពីការធ្វើរបាយការណ៍អនុវត្តចំណូលប្រចាំសប្តាហ៍ និង ប្រចាំខែ អង្គភាពនីមួយៗត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាសស្តីពីការអនុវត្តន៍ចំណូលរបស់ខ្លួនសំរាប់ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ និង មានវិធានការតាមរយៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយលើកឡើងពីលទ្ធផលដែលសំរេចបាន និង ចំណុចខ្វះខាតដែលបានកត់សំគាល់ ព្រមទាំងលើកឡើងនូវសំណូមពរ និង អនុសាសន៍ដើម្បីកែលំអ និង បង្កើនប្រសិទ្ធភាពប្រមូលចំណូល ។

៨- លើសពីនេះទៅទៀត ដើម្បីធានាការប្រមូលចំណូលតាមគោលនយោបាយនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបាន ដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖

- *វិធានការពង្រឹងសមត្ថភាពប្រមូល និង គ្រប់គ្រងចំណូល* តាមរយៈការពង្រឹងសមត្ថភាពកសាងគោលនយោបាយ និង យន្តការគ្រប់គ្រង ការបង្កើតក្របខ័ណ្ឌ និង ជំរុញការកសាងវិធានការគៀរគរចំណូលតាមមូលដ្ឋាន ការជំរុញការកសាងការព្យាករណ៍ចំណូលរយៈពេលមធ្យម ការរៀបចំយន្តការ និង ផែនការប្រមូល និង តឹងទាររាល់បំណុលសារពើពន្ធ និង មិនមែនសារពើពន្ធ និង ការពង្រឹង ការធ្វើសវនកម្ម និង អធិការកិច្ចលើការប្រមូលចំណូល ។ ជាក់ស្តែង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងជំរុញការអនុវត្តន៍នូវបណ្តាសកម្មភាពមួយចំនួនដូចជា៖

  - កសាង និង រៀបចំដាក់អោយអនុវត្តនូវបង្កាន់ដៃជាតិមួយដែលឯកភាព សំរាប់ប្រើប្រាស់ក្នុងការចុះបញ្ជី និង តាមដានការគ្រប់គ្រងលើការប្រមូលចំណូលជាតិគ្រប់ប្រភេទ ។
  - រៀបចំ និង ណែនាំអោយអនុវត្តប្រកបដោយប្រសិទ្ធភាពនូវបទបញ្ជា និង វិន័យលើការប្រមូលចំណូលថវិការដ្ឋគ្រប់ប្រភេទ ជាពិសេស ចំណូលមិនមែនសារពើពន្ធ ។
  - កសាងបណ្តាជំរើសនានាដើម្បីពង្រឹងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការកសាងគោលនយោបាយ និង យន្តការគ្រប់គ្រងកម្មវិធីសមាហរណកម្មពេញលេញនៃការគៀរគរធនធានថវិកា ជាពិសេសការបង្កើនសមត្ថភាពវិភាគព្យាករណ៍ និង ស្វែងរកប្រភពចំណូលថ្មី ។
  - បង្កើតក្របខ័ណ្ឌសំរាប់គៀរគរ និង បែងចែកចំណូលទៅតាមគ្រប់លំដាប់ថ្នាក់រដ្ឋបាល និង ផ្តល់ការណែនាំដល់ការកសាងវិធានការសំដៅបង្កើនធនធានទៅតាមខេត្ត ក្រុង និង ឃុំសង្កាត់ ។
  - កសាងបណ្តាជំរើសសំរាប់រយៈពេលមធ្យម និង វែងពាក់ព័ន្ធនឹងកម្មវិធីសមាហរណកម្មនៃការគៀរគរធនធានថវិកាសំដៅបំរើឱ្យការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ។
  - កសាងបណ្តាជំរើសក្នុងការធ្វើសមាហរណកម្មការគៀរគរធនធានថវិកា ដើម្បីកំណត់បញ្ចូលទៅក្នុងដំណើរការកសាងថវិកាជាតិ និង ដំណើរការត្រួតពិនិត្យឡើងវិញនៃការអនុវត្តន៍ថវិកាជាតិ ។

- កំណត់ឱ្យបានច្បាស់លាស់នូវបំណុលសារពើពន្ធ និង បំណុលនៃចំណូលមិនមែនសារពើពន្ធ ដើម្បីរៀបចំផែនការប្រមូល និង តឹងទារឱ្យមានប្រសិទ្ធភាព ។
- ពង្រឹងការងារសវនកម្ម ទាំងសវនកម្មផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័នសាមីនីមួយៗ ទាំងសវនកម្មផ្ទៃក្រៅ និង ការងារអធិការកិច្ច ទាំងអធិការកិច្ចរបស់រាជរដ្ឋាភិបាល ទាំងអធិការកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លើការគ្រប់គ្រងថវិកាជាតិជាពិសេសលើការប្រមូលចំណូល ។

• ***វិធានការពង្រឹងការប្រមូលចំណូលគយ និង រដ្ឋាករ*** តាមរយៈការជំរុញការអនុវត្តន៍ច្បាប់ និង បទបញ្ញាតិលើការទប់ស្កាត់ និង បង្ក្រាបការគេចពន្ធ ការជំរុញការកសាងគោលនយោបាយគយ និង រដ្ឋាករ និង សេចក្តីណែនាំការអនុវត្តន៍នីតិវិធីគយ ការជំរុញការបណ្តុះបណ្តាលជំនាញដល់មន្ត្រីគយ ការបង្កើនសមត្ថភាពវិភាគចំណូល និង ការផ្តល់តួលេខចំណូលដោយសុក្រិត និង បច្ចុប្បន្នភាព ការជំរុញការអនុវត្តន៍គំរោងស្វ័យប្រវត្តិកម្មប្រតិបត្តិការគយ និង រដ្ឋាករ ការបន្តជំរុញការអនុវត្តការប្រមូលពន្ធគយតាមប្រព័ន្ធធនាគារ និង ការជំរុញការកែលំអរចនាសម្ព័ន្ធនៃការផ្តល់លាភកា និង ការលើកទឹកចិត្តដល់មន្ត្រីគយ ។ ជាពិសេស ការអនុវត្តន៍នូវបណ្តាសកម្មភាពជាក់ស្តែងមួយចំនួនដូចជា៖

- ការកសាង និង ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិខាងផ្នែកគយជាមួយប្រទេសដៃគូរពាណិជ្ជកម្មអន្តរជាតិ ជាពិសេសប្រទេសជាប់ព្រំដែន ដើម្បីទប់ស្កាត់អំពើល្មើសគេចពន្ធតាមរយៈការផ្តល់ព័ត៌មាន និង ការបញ្ជាក់ទៅវិញទៅមកពាក់ព័ន្ធនឹងការនាំចេញ- នាំចូលមុខទំនិញមានវេទយិតភាពខ្ពស់លើចំណូល ។
- ចាត់វិធានការទប់ស្កាត់ការជ្រាបចូលទីផ្សារនៃទំនិញដែលនាំចូលតាមរបបអនុគ្រោះនានា ដោយដាក់អោយដំណើរការនូវប្រព័ន្ធជំរះបញ្ជីច្បាស់លាស់ ។
- ពង្រឹងយន្តការត្រួតពិនិត្យទំនិញមុនពេលផ្ទុកបន្ថែមទៀត ដើម្បីកាត់បន្ថយជាអតិបរមានូវទំនិញនាំចូលដែលមិនឆ្លងការត្រួតពិនិត្យទំនិញមុនពេលផ្ទុកអោយបានត្រឹមត្រូវ ។
- ជំរុញការអនុវត្តន៍យន្តការឆ្លងកាត់ជាតិ ដើម្បីយកទំនិញសំខាន់ៗមួយចំនួនមកបំពេញបែបបទនៅជិតតំបន់ប្រើប្រាស់ ជាសវាងការចំណាយមិនចាំបាច់នានានៅតាមច្រក និង តាមដងផ្លូវងាយស្រួលដល់ផ្នែកផ្សេងទៀតជួយឃ្លាំមើល និង សង្កេតការណ៍ ។
- កែសំរួលនិតិវិធីត្រួតពិនិត្យរបស់គយអោយកាន់តែមានប្រសិទ្ធភាព លើទំនិញនាំចូលនាពេលបំពេញបែបបទបញ្ចេញទំនិញ ពេលដឹកជញ្ជូន ពេលសន្និធិ និង ពេលចរាចរចែកចាយ ។
- បន្តជំរុញ និង ពង្រីកការអនុវត្តន៍ការប្រមូលចំណូលតាមរយៈមូលប្បទានប័ត្រ និង ការផ្ទេរដោយត្រង់ទៅធនាគារជាតិ ។
- រៀបចំ និង អនុវត្តការធ្វើសវនកម្មក្រោយការយកទំនិញចេញពីគយ ដើម្បីធានាភាពត្រឹមត្រូវនៃប្រតិបត្តិការគយ ។

- រៀបចំកម្មវិធីបណ្តុះបណ្តាលធនធានមនុស្ស រួមទាំងការជ្រើសរើស និង ហ្វឹកហ្វឺនមន្ត្រី និង ភ្នាក់ងារគយ និង រដ្ឋាករ ។
- អនុវត្តយុទ្ធសាស្ត្រចាប់បង្ក្រាប និង គោលការណ៍គ្រប់គ្រងហានិភ័យដើម្បីកាត់បន្ថយការគេចពន្ធ និង បណ្តាសកម្មភាពខុសច្បាប់ផ្សេងៗនៅតាមព្រំដែន ។
- ពង្រឹងក្របខ័ណ្ឌគតិយុត្តិដោយផ្អែកលើច្បាប់គយថ្មី ដោយការអនុវត្តន៍យ៉ាងហ្មត់ចត់ ក្នុងនោះ រួមមានទាំងការកសាងគោលនយោបាយគយ និង រដ្ឋាករ និង ការចងក្រងសេចក្តីណែនាំអនុវត្តនីតិវិធីគយ ។
- អនុវត្តកម្មវិធីគ្រប់ជ្រុងជ្រោយរបស់គយក្នុងការវិភាគលើចំណូល និង ការផ្តល់តួរលេខចំណូល និង ស្ថិតិពាណិជ្ជកម្មប្រកបដោយបច្ចុប្បន្នភាព និង សុក្រឹតភាព ។
- ជំរុញការអនុវត្តន៍គំរោងបំពាក់បច្ចេកវិទ្យាពត៌មានដល់ទីចាត់ការគយ និង រដ្ឋាករ ហើយរៀបចំវិធានការរយៈពេលខ្លីសំរាប់ការអនុវត្តន៍កម្មវិធីស្វ័យប្រវត្តិកម្មគយ រួមទាំងការរៀបចំបង្កើតមូលដ្ឋានច្បាប់ និង នីតិវិធីដែលមានការពាក់ព័ន្ធនឹងការបណ្តុះបណ្តាល និង ការរៀបចំគំរោងផង ។
- កំណត់ និង អនុវត្តវិធានការពង្រឹងស្ថាប័នគយ រួមទាំងការកែលំអរចនាសម្ព័ន្ធនៃការផ្តល់កំរៃ និង ការលើកទឹកចិត្តដល់មន្ត្រីគយ និង ការអភិវឌ្ឍន៍កម្មវិធីអភិបាលកិច្ចល្អផង ។

• *វិធានការពង្រឹងការប្រមូលចំណូលពន្ធដារ* តាមរយៈការពង្រឹងការអនុវត្តន៍ច្បាប់ស្តីពីសារពើពន្ធ ការ បន្តពង្រីកមូលដ្ឋានពន្ធ រួមមានការបន្តពង្រីករបបពិតទៅតាមខេត្ត និង ពង្រឹងការអនុវត្តន៍អាករលើតំលៃបន្ថែម ការពង្រឹងសមត្ថភាពវិភាគព្យាករណ៍ និង ការរៀបចំគោលនយោបាយពន្ធដារ ការបង្កើនការប្រើប្រាស់ប្រព័ន្ធធនាគារក្នុងការបង់ពន្ធ ជាពិសេសចំពោះការបង់ពន្ធប្រភេទធំ ការពង្រឹងការគ្រប់គ្រងបំណុលពន្ធ និង អនុវត្ត ការតឹងទារបំណុលពន្ធដារ និង ការពង្រឹងការធ្វើសវនកម្មពន្ធ ជាពិសេសចំពោះអ្នកជាប់ពន្ធប្រភេទធំ ។ ជាពិសេស ការអនុវត្តន៍ នូវបណ្តាសកម្មភាពជាក់ស្តែងមួយចំនួនដូចជាៈ

- រៀបចំ និង ដាក់អោយអនុវត្តការប្រមូលពន្ធលើអចលនវត្ថុ ។
- ពង្រឹងការប្រមូលចំណូលពន្ធតាមរយៈការអនុវត្តន៍ច្បាប់ស្តីពីសារពើពន្ធ និង ច្បាប់ដែលមានការពាក់ព័ន្ធ ដូចជាច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង បទបញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ។
- ពង្រឹងការគ្រប់គ្រងប្រមូលអាករពិសេស អាករលើតំលៃបន្ថែម និង យន្តការបង្វិលសងអាករលើតម្លៃបន្ថែម ។
- កែលំអការវិភាគ និង ការព្យាករណ៍លើចំណូលពន្ធដារ ក្នុងទិសដៅបង្កើតបណ្តាជំរើសគោលនយោបាយថ្មីៗ ដើម្បីបង្កើនចំណូលពន្ធ ។

- កំណត់នីតិវិធីឱ្យបានច្បាស់លាស់ សំរាប់ពង្រឹងការផ្តល់ពត៌មានទៅវិញទៅមក ជាពិសេសពត៌មានអំពីអ្នកបង់ពន្ធប្រភេទធំរវាងទីចាត់ការគយ និង រដ្ឋាករ និង នាយកដ្ឋានពន្ធដារ ។
- ការបង្កើនការប្រើប្រាស់ប្រព័ន្ធធនាគារក្នុងភិរតអតិបរមាដើម្បីសំរួលដល់ការបង់ពន្ធ ជាពិសេសចំពោះអ្នកជាប់ពន្ធប្រភេទធំ និង មធ្យម ។
- ពង្រឹងឱ្យបានគ្រប់ជ្រុងជ្រោយនូវសវនកម្មពន្ធ ពិសេសចំពោះអ្នកជាប់ពន្ធប្រភេទធំ និង មធ្យម។
- ពង្រឹងការគ្រប់គ្រងបំណុលពន្ធ និង អនុវត្តយ៉ាងហ្មឹងម៉ាត់នូវការតឹងទារបំណុលពន្ធដារ ក្នុងនោះរួមមានការអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាពត៌មានសំរាប់កិច្ចប្រតិបត្តិការគ្រប់គ្រង និង ការធ្វើសវនកម្មពន្ធនៅនឹងកន្លែង ព្រមទាំងការជំរះបញ្ជីអ្នកជាប់ពន្ធផងដែរ ។
- បន្តអនុវត្តវិធានការពង្រឹងនាយកដ្ឋានពន្ធដារ រួមទាំងការរៀបចំរចនាសម្ព័ន្ធឡើងវិញ ការជ្រើសរើសមន្ត្រីថ្មីបន្ថែម ការកែលំអសេវាបំរើឱ្យអ្នកជាប់ពន្ធ ការអនុវត្តន៍កម្មវិធីបណ្តុះបណ្តាលការធ្វើសវនកម្មផ្តោតក្នុងការបំពាក់នូវទុក្ខសំភារៈចាំបាច់ផ្សេងៗ ។ល។
- បង្កើនការផ្ទៀងផ្ទាត់ពត៌មានដើម្បីស្វែងរកផលរបរនៅក្នុងរបបម៉ៅការដែលត្រូវផ្ទេរទៅរបបពិត។

• *វិធានការពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធ* តាមរយៈការពង្រឹងក្របខ័ណ្ឌច្បាប់ និង វិធានការគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ ការពង្រឹងការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ការអនុវត្តន៍វិធានការដាក់វិន័យចំពោះក្រសួងដែលមិនបង់ចំណូលចូលថវិការដ្ឋតាមកាលកំណត់ និង ការអនុវត្តន៍យ៉ាងហ្មឹងម៉ាត់ និង ជាប្រចាំនូវការងារសវនកម្ម និង អធិការកិច្ចលើកាតព្វកិច្ចបង់ចំណូលមិនមែនសារពើពន្ធរបស់ក្រសួង- ស្ថាប័ន និង សហគ្រាសសាធារណៈគ្រប់ប្រភេទ ។ ជាពិសេស ការអនុវត្តន៍នូវបណ្តាសកម្មភាពជាក់ស្តែងមួយចំនួនដូចជា៖

- រៀបចំ និង ដាក់អោយអនុវត្តនូវអនុក្រឹត្យស្តីពីការគ្រប់គ្រង និង ការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ។
- ចុះសិក្សា និង ស្រាវជ្រាវរាល់បំណុលទាំងអស់ ដើម្បីរៀបចំគោលការណ៍ និង នីតិវិធីតឹងទារ ឬ ដោះស្រាយតាមផ្លូវច្បាប់ចំពោះបំណុលកុំរ៉ៃ
- ដាក់ចេញនូវវិធានការជាបន្ទាន់ដើម្បីពង្រឹងក្របខ័ណ្ឌច្បាប់ និង ស្ថាប័ន សំរាប់ការគ្រប់គ្រង និង ប្រមូលចំណូលមិនមែនសារពើពន្ធ ។
- ពង្រឹងការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ។
- ពង្រឹងការគ្រប់គ្រងឯកជនភាវូបនីយកម្មនៃទ្រព្យសម្បត្តិរដ្ឋឱ្យស្របទៅតាមច្បាប់ និង បទបញ្ញត្តិជាធរមាន ។
- ដាក់ចេញ និង អនុវត្តជាបន្ទាន់ឱ្យមានប្រសិទ្ធភាពនូវៈ (១)- វិធានការពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធពីការជួល ឬ លក់អចលនទ្រព្យ រួមទាំងការពង្រឹងនីតិវិធីនៃការជួល និង ការចុះកិច្ចសន្យាផង (២)- វិធានការពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធពីសហគ្រាសសាធារណៈ តាមរយៈការពង្រឹងក្របខ័ណ្ឌនៃការគ្រប់គ្រងសហគ្រាសទាំងអស់នោះ (៣)- វិធាន

ការពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធពីការលក់ទំនិញសាធារណៈ និង ការផ្តល់សេវាសាធារណៈ (៤)- វិធានការពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធពីការគ្រប់គ្រងធនធានធម្មជាតិគ្រប់ប្រភេទ ។

- ពង្រឹងប្រព័ន្ធត្រួតពិនិត្យ និង ប្រមូលចំណូលពីអាជីវកម្មឆ្នោត និង ល្បែងភ្នាល់ផ្សេងៗ ដោយសិក្សាពីបទពិសោធន៍អន្តរជាតិ ពាក់ព័ន្ធនឹងជំរើសដែលអាចបង្កើនចំណូលពីអាជីវកម្មឆ្នោត និងល្បែងភ្នាល់ទាំងអស់នោះ ។
- ពង្រឹងក្របខ័ណ្ឌច្បាប់ក្នុងការត្រួតពិនិត្យសកម្មភាពប្រតិបត្តិការកាស៊ីណូ និង ពង្រឹងការប្រមូលចំណូលពីកាស៊ីណូឱ្យបានកើនឡើងសមស្របនឹងចំណូលជាក់ស្តែងនៃអាជីវកម្មក្នុងវិស័យនេះ ក្នុងនោះរួមមានការពង្រឹងសមត្ថភាពរបស់ស្ថាប័ន និង មន្ត្រីដែលទទួលបន្ទុកការងារប្រមូលចំណូលនេះផងដែរ ។
- ដាក់ចេញ និង អនុវត្តនូវប្រព័ន្ធដែលផ្តល់អំណាចដល់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការអនុម័តជាចុងក្រោយលើរាល់កិច្ចព្រមព្រៀង និង កិច្ចសន្យាសម្បទានគ្រប់ប្រភេទ ដើម្បីបង្កើនចំណូលពីសម្បទានរបស់រដ្ឋ និង ដើម្បីការពារផលប៉ះពាល់អាក្រក់ដល់ថវិកាជាតិ ។
- ដាក់ចេញ និង អនុវត្តជាបន្ទាន់ឱ្យបានប្រកបដោយប្រសិទ្ធភាពនូវវិធានការដាក់វិន័យ ចំពោះក្រសួង-ស្ថាប័នឬមន្ត្រីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ ដែលមិនព្រមបង់ចំណូលចូលរតនាគារជាតិ ឬ លួចលាក់ចំណូលទុកចាយនៅក្រៅបរិបថនៃថវិកាជាតិ ឬ ទុកចាយដោយខុសនីតិវិធីនៃច្បាប់ហិរញ្ញវត្ថុជាធរមាន ។
- អនុវត្តយ៉ាងហ្មត់ចត់ និង ជាប់ជាប្រចាំនូវសវនកម្ម និង អធិការកិច្ចលើការអនុវត្តន៍កាតព្វកិច្ចបង់ចំណូលពុំមែនសារពើពន្ធរបស់គ្រប់ក្រសួង-ស្ថាប័ន និង សហគ្រាសសាធារណៈ ដែលមានការពាក់ព័ន្ធ ។

## ខ- ការអនុវត្តន៍ចំណាយថវិកា

៩- ដើម្បីធានាដល់ការអនុវត្តន៍ថវិកាឆ្នាំ ២០០៦ ប្រកបដោយប្រសិទ្ធភាព និង សំរេចបានតាមគោលដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ការគ្រប់គ្រងចំណាយក៏នឹងត្រូវបានបន្តពង្រឹងបន្ថែមទៀត ជាពិសេស ការគោរពអោយបានដាច់ខាតនូវវិន័យថវិកាទាំង ១១ខ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ។ ទន្ទឹមនឹងនេះ ត្រូវបន្តពង្រឹងការអនុវត្តន៍អភិបាលកិច្ចល្អក្នុងការអនុវត្តន៍ចំណាយ និង ការវិភាជន៍ចំណាយ ការគ្រប់គ្រងការអនុវត្តន៍ថវិកា ការគ្រប់គ្រងការងារលទ្ធកម្មសាធារណៈ និង ការអនុវត្តឱ្យបានហ្មត់ចត់នូវរាល់ការងារកែទំរង់ហិរញ្ញវត្ថុសាធារណៈ ជាពិសេសការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ ក្រសួង-ស្ថាប័នទាំងអស់ទាំងនៅរដ្ឋបាលកណ្តាល ទាំងនៅខេត្ត-ក្រុងត្រូវប្រកាន់ខ្ជាប់ និង គោរពឱ្យបានហ្មត់ចត់បំផុតនូវវិន័យថវិកា និងនីតិវិធីចំណាយថវិកា ដើម្បីធានាឱ្យបាននូវតុល្យភាពថវិកា ជាពិសេសត្រូវអនុវត្តនូវវិធានការដូចខាងក្រោម៖

- *ទីមួយ:* ត្រូវគោរពតាមឥណទានថវិកា ដែលត្រូវបានកំណត់ដោយច្បាប់ជាអាទិ៍ៈ

  + មិនត្រូវលើកសំណើចំណាយណាដែលគ្មានការគ្រោងទុកនៅក្នុងថវិកា ឬ គ្មានឥណទានថវិកានៅសល់ទំនេរ ។

  + មិនត្រូវអោយមានចំណាយលើសពីឥណទានថវិកាដែលមានលក្ខណៈកំរិតកំណត់ ។

  + មិនត្រូវអនុវត្តនូវសកម្មភាព ដែលនាំអោយមានការជ្រើសរើសបុគ្គលិកថ្មី ឬ បុគ្គលិកជាប់កិច្ចសន្យានៅក្នុងឆ្នាំដែលកំពុងអនុវត្ត ដោយគ្មានការគ្រោងទុកក្នុងថវិកា ឬ គ្មានសេចក្តីសំរេចពីរាជរដ្ឋាភិបាល។

  + មិនត្រូវលើកសំណើចំណាយបន្ថែមប្រសិនបើគ្មានការសន្សំសំចៃពីខ្ទង់ចំណាយដទៃទៀតមកធានា។

- *ទីពីរ:* ត្រូវអនុវត្តន៍ទៅតាមកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសឱ្យបានហ្មត់ចត់ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវធ្វើកម្មវិធីចំណូល- ចំណាយជាក់ស្តែងប្រចាំត្រីមាស ដែលកម្មវិធីចំណូលចំណាយនេះនឹងត្រូវធ្វើការត្រួតពិនិត្យឡើងវិញប្រចាំត្រីមាស ដោយឈរលើមូលដ្ឋាននៃថវិកា ដែលត្រូវបានកំណត់ដោយច្បាប់ ហើយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអាចតម្រឹមចំណាយថវិកាទៅតាមសមិទ្ធិផលជាក់ស្តែងនៃការប្រមូលចំណូល ដើម្បីធានានូវតុល្យភាពថវិកា ធានាប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់ និង ធានាភាពជឿទុកចិត្តលើថវិកា ។

- *ទីបី:* ត្រូវគោរពនីតិវិធីក្នុងការគ្រប់គ្រងចំណាយថវិកាៈ

  + មិនត្រូវអនុញ្ញាតឱ្យមានការធានាចំណាយ និង ការផ្តល់ទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេ ប្រសិន បើគ្មានការស្នើសុំជាលាយលក្ខណ៍អក្សរពីអាណាប័កដើមខ្សែ ឬ អាណាប័កផ្ទេរសិទ្ធិ ទោះបីចំណាយនោះមានកត់ត្រាទុកនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុក៏ដោយ ។

  + មិនត្រូវអនុញ្ញាតឱ្យមានការលើកលែងគោលការណ៍នៃបរិបថចំណាយ ការសន្យាចំណាយ ការជំរះបញ្ជី ការធ្វើអាណត្តិបើកប្រាក់ និង ការទូទាត់ លើកលែងតែមានករណីដែលរាជរដ្ឋាភិបាលសំរេចដោយឡែក ។

  + មិនត្រូវធ្វើការធានាចំណាយ ប្រសិនបើគ្មានឥណទានថវិកានៅសល់ទំនេរ គឺត្រូវធ្វើការសន្យាចំណាយទៅតាមឥណទានថវិកាដែលមាន ។

  + ត្រូវផ្តល់ធានាចំណាយ និង ចេញអាណត្តិបើកប្រាក់ ទៅតាមកម្មវិធីចំណូល- ចំណាយដែលបានកំណត់ លើកលែងតែក្នុងករណីចាំបាច់ដែលមានការស្នើសុំពីក្រសួងចំណាយ និង មានការឯកភាពពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

  + មិនត្រូវអនុវត្តចំណាយណាដែលគ្មានលិខិតយុត្តិកម្មគ្រប់គ្រាន់សំរាប់បង្ហាញមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដើម្បីធ្វើជាមូលដ្ឋានគតិយុត្តិនៃសំណើចំណាយថវិកា ។

+ មិនអាចធ្វើអាណត្តិបើកប្រាក់ និង មិនអាចបញ្ជូនអាណត្តិបើកប្រាក់នោះទៅរតនាគារជាតិបានឡើយ ប្រសិនបើលិខិតយុត្តិការផ្លូវការមានលក្ខណៈមិនគ្រប់គ្រាន់ ។

+ អាចផ្តល់ថវិកាបុរេប្រទានបាន តែក្នុងករណីចាំបាច់ជាបន្ទាន់ ហើយមានឥណទានសល់ទំនេរសំរាប់ចេញអាណត្តិទូទាត់បាន ក្រោយពីប្រតិបត្តិការចំណាយរួច ។

+ អាចផ្តល់មូលនិធិជួសជុល-ថែទាំផ្លូវថ្នល់បាន លុះត្រាតែមានឥណទានសល់ទំនេរនៅក្នុងគណនីមូលនិធិ ។

១០- ដើម្បីឱ្យការអនុវត្តន៍ចំណាយថវិការដ្ឋប្រព្រឹត្តទៅបានទាន់ពេលវេលា និង ជៀសវាងការចំណាយតិចនៅដើមឆ្នាំ ហើយទៅប្រមូលផ្តុំចំណាយច្រើននៅចុងឆ្នាំ និង ម្យ៉ាងវិញទៀត ដើម្បីរក្សាតុល្យភាពថវិកាឱ្យបានរឹងមាំផងនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញនៅតាមខេត្ត-ក្រុង ឱ្យដំណើរការអនុវត្តនីតិវិធីចំណាយ ដូចជាការស្នើសុំធានាចំណាយ និង អនុវត្តវិធីសាស្ត្រលទ្ធកម្មសាធារណៈដូចតទៅ÷

• រដ្ឋមន្ត្រីដែលជាអាណាប័កដើមខ្សែ ត្រូវប្រញាប់ប្រញាល់ធ្វើប្រកាសស្តីពីការតែងតាំងអាណាប័កផ្ទេរសិទ្ធិ និង ការផ្ទេរឥណទានថវិកាជូនអភិបាលខេត្ត-ក្រុង ដើម្បីឱ្យមន្ទីរជំនាញរបស់ខ្លួននៅតាមខេត្ត- ក្រុង អាចមានលទ្ធភាពអនុវត្តនូវនីតិវិធីចំណាយបានទាន់ពេលវេលា ។

• ចំណាយថវិការដ្ឋក្នុងការទិញសំភារៈ ជួលសេវា ជួសជុល និង សាងសង់ ត្រូវតែអនុវត្តឱ្យបានហ្មឹងម៉ាត់តាមគោលការណ៍ និង និតិវិធីលទ្ធកម្មសាធារណៈ ។ ចំពោះការអនុវត្តនីតិវិធីដេញថ្លៃសាធារណៈ ជាដំបូងក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវពិនិត្យមើលឥណទានថវិកាឆ្នាំ ២០០៦ របស់ខ្លួនមានប៉ុន្មាននៅជំពូកណាខ្លះ រួចលើកសំណើសុំគោលការណ៍ធានាចំណាយមួយឆមាសម្តង ក្នុងការផ្គត់ផ្គង់ទំនិញសេវាការជួសជុល ការសាងសង់ មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត-ក្រុងឱ្យបាននៅដើមឆ្នាំ និង ដើមឆមាស ទី២ ដើម្បីមានពេលវេលាគ្រប់គ្រាន់សំរាប់ធ្វើការងារដេញថ្លៃជាសាធារណៈ ។ កន្លងមក សាម៉ីក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង មានការយឺតយ៉ាវក្នុងការស្នើសុំធានាចំណាយ ដែលជាហេតុបណ្តាលឱ្យការងារលទ្ធកម្មត្រូវអូសបន្លាយ ហើយការងារទូទាត់ត្រូវពន្យារដល់ចុងឆ្នាំនាំឱ្យចំណាយកើនឡើងគំហុកនៅចុងឆ្នាំ ។ សូមបញ្ជាក់ថា ការស្នើសុំធានាចំណាយសំរាប់អនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ មិនទាក់ទងដល់កម្មវិធីចំណាយទេ គឺទាក់ទងតែដល់ឥណទានថវិកាដែលមានកំណត់នៅក្នុងសៀវភៅថវិកាតែប៉ុណ្ណោះ ។

• ការចេញអាណត្តិទូទាត់ ត្រូវធ្វើឡើងក្រោយពីការប្រគល់ទទួល ដែលបានកំណត់នៅក្នុងកិច្ចសន្យា ។ ក្នុងករណីតម្លៃកិច្ចសន្យាមានចំនួនទឹកប្រាក់ច្រើនដល់រាប់ពាន់លានរៀលនោះ ការចេញអាណត្តិទូទាត់ត្រូវធ្វើឡើងជាច្រើនជំហានទៅតាមលទ្ធភាពនៃសាច់ប្រាក់ ។

• តំលៃសរុបនៃកិច្ចសន្យាលទ្ធកម្ម មិនអនុញ្ញាតឱ្យលើសពីឥណទានថវិកាដែលបានផ្តល់ការធានាចំណាយ ឬ ចំនួនទឹកប្រាក់ដែលបានយល់ព្រមផ្តល់មុនបណ្តោះអាសន្នតាមអាណត្តិបើកប្រាក់ឡើយ ។

• មិនអនុញ្ញាតិឱ្យធ្វើការប្រគល់ទទួល (ទំនិញ-សំណង់) ដោយគ្មានកិច្ចសន្យាលទ្ធកម្មឡើយ លើកលែងតែមានការសំរេចដោយឡែកដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ព្រោះកិច្ចសន្យាជាមូលដ្ឋានសំខាន់ និងចាំបាច់បំផុតសំរាប់ធ្វើការទូទាត់ ព្រមទាំងធ្វើការផ្ទៀងផ្ទាត់លក្ខណៈបច្ចេកទេស គុណភាព តំលៃ រយៈពេលផ្គត់ផ្គង់ ឬ សាងសង់ ដែលភាគីទាំងពីរបានព្រមព្រៀងគ្នា ។

• ក្នុងករណីចាំបាច់ដែលតំរូវឱ្យមានការផ្លាស់ប្តូរបញ្ជីប៉ាន់តំលៃ ឬ លក្ខណៈបច្ចេកទេស (ទំនិញ ឬ សំណង់) ខុសពីឧបសម្ព័ន្ធនៃកិច្ចសន្យា ត្រូវតែមានការឯកភាពជាលាយលក្ខអក្សររបស់ភាគីទាំងពីរ និង មានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

• ក្នុងករណីការងារដែលទទួលអនុវត្តដោយអង្គភាពរដ្ឋ ត្រូវរក្សាចំនួនទឹកប្រាក់ ១០% នៃតំលៃសរុបរបស់កិច្ចសន្យាទុកជាការធានាគុណភាពជំនួសប្រាក់កក់រហូតដល់ផុតរយៈពេលធានាគុណភាព ទើបធ្វើការទូទាត់ជូនបង្គ្រប់បញ្ចប់ បន្ទាប់ពីមានកំណត់ហេតុប្រគល់ទទួលបញ្ជាក់ថាបានអនុវត្តត្រឹមត្រូវតាមកិច្ចសន្យា ។

• មុនការអនុវត្តនីតិវិធីសាស្ត្រលទ្ធកម្ម សាមីក្រសួង-ស្ថាប័ន ត្រូវផ្ញើលិខិតអញ្ជើញ និង បញ្ជីប៉ាន់តំលៃមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ យ៉ាងយឺតបំផុតឱ្យបានមុនមួយសប្តាហ៍ ។

១១- ទន្ទឹមនឹងការអនុវត្តន៍ចំណាយទៅតាមកម្មវិធីចំណូល-ចំណាយ ដំណើរការទូទាត់អាណត្តិបើកប្រាក់ ត្រូវផ្តល់អាទិភាពទៅលើចំណាយចាំបាច់ជាប្រចាំ មានដូចជាប្រាក់បៀវត្ស ប្រាក់អាហារូបករណ៍ ប្រាក់ឧបត្ថម្ភតាមគោលនយោបាយសង្គមកិច្ច ប្រាក់របបអ្នកជំងឺ ការប្រាក់ សងបំណុល ទឹក ភ្លើង ទូរស័ព្ទ វិភាគទានឱ្យអង្គការអន្តរជាតិនានា និង ចំណាយបដិភាគរួមចំណែកជាមួយការវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ និងបន្ទាប់មកត្រូវផ្អែកលើការទូទាត់ដែលមានចែងក្នុងកិច្ចសន្យាលទ្ធកម្មសាធារណៈ ។ ទន្ទឹមនឹងនេះ ត្រូវអនុវត្តវិធានការមួយចំនួន ក្នុងគោលបំណងត្បិតត្បៀត សន្សំសំចៃលើចំណាយសំរាប់កិច្ចដំណើរការរបស់ក្រសួង-ស្ថាប័នជាពិសេសចំណាយលើការប្រើប្រាស់សំភារៈការិយាល័យ ប្រេងឥន្ធនៈ ទឹក ភ្លើង ទូរស័ព្ទ និង ចំណាយផ្សេងៗទៀតដែលមិនសូវចាំបាច់ ។ ម៉្យាងវិញទៀត ត្រូវពង្រឹងយន្តការដើម្បីធានាលើកកំពស់ប្រសិទ្ធភាពអនុវត្តចំណាយសំរាប់កម្មវិធីសកម្មភាពជាអាទិភាព ជាពិសេស សំរាប់វិស័យសុខាភិបាល អប់រំ កសិកម្ម ធនធានទឹក និងអភិវឌ្ឍន៍ជនបទ ។ ចំណែកឯចំណាយផ្សេងៗទៀត ដែលមានលក្ខណៈបន្ទាប់បន្សំត្រូវបើកផ្តល់ទៅតាមលទ្ធភាពសាច់ប្រាក់របស់រតនាគារជាតិ ។

១២- ចំពោះចំនួនក្របខ័ណ្ឌ និង ប្រាក់បៀវត្សរបស់មន្ត្រីរាជការស៊ីវិល មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត-ក្រុង ត្រូវតែពិនិត្យអនុវត្តតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល អនុក្រឹត្យលេខ ៣៤

អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការកែសម្រួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និង ប្រាក់ក្នុងវិស័យអប់រំ អនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការកែប្រែតំលៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល អនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការកែប្រែប្រាក់ បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និង តារាងទូទាត់ប្រាក់បៀវត្សតាមប្រព័ន្ធពតិមានវិទ្យាដែលចេញដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

III. ការរៀបចំគម្រោងថវិកាចំណូល-ចំណាយប្រចាំត្រីមាស

១៣- ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង មានភារកិច្ចរៀបចំគំរោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសសំរាប់រយៈពេលពេញ ១ ឆ្នាំ ដែលមានបែងចែកលំអិតទៅតាមខែ ដោយឈរលើមូលដ្ឋាននៃឥណទានដែលត្រូវបានកំណត់ដោយច្បាប់ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ដើម្បីពិនិត្យ និង វាយតំលៃ ដោយផ្អែកទៅលើតំរូវការ និង លទ្ធផលចំណូល-ចំណាយជាក់ស្តែង ដើម្បីដាក់ចេញជាកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសសំរាប់ការអនុវត្តន៍ ។ ដោយឡែក មន្ទីរជំនាញខេត្ត-ក្រុង ត្រូវផ្ញើរមកក្រសួង- ស្ថាប័នតាមខ្សែបណ្តោយរបស់ខ្លួននូវគំរោងកម្មវិធីចំណូល- ចំណាយប្រចាំត្រីមាសនេះមួយច្បាប់ ដើម្បីការគ្រប់គ្រង និង តាមដានការអនុវត្តន៍ ។

១៤- ដើម្បីឱ្យនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រៀបចំឱ្យបានល្អ និង ត្រឹមត្រូវនូវការបែងចែកឥណទានថវិកាតាមកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស និង អនុវត្តឱ្យបានសំរេចនូវការអនុវត្តន៍ចំណូល- ចំណាយថវិកាតាមទិសដៅរបស់រាជរដ្ឋាភិបាល ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញ ខេត្ត-ក្រុង ត្រូវអនុវត្តឱ្យបានហ្មឺងម៉ាត់នូវនីតិវិធីដូចខាងក្រោម៖

- ក្នុងរយៈពេលចាប់ពីថ្ងៃទី ១៥ ដល់ថ្ងៃទី ២០ នៃខែចុងត្រីមាសនីមួយៗ នាយកដ្ឋានពន្ធដារ ទីចាត់ការគយ និង រដ្ឋាករ រតនាគារ នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ក្រសួង-ស្ថាប័ន និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវផ្ញើមកនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវរបាយការណ៍អំពីលទ្ធផលនៃការអនុវត្តន៍កម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសកន្លងទៅ និង គំរោងកម្មវិធីចំណូល- ចំណាយប្រចាំត្រីមាសបន្ទាប់ ។

- នាយកដ្ឋានពន្ធដារ ទីចាត់ការគយ និង រដ្ឋាករ រតនាគារ នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ក្រសួង-ស្ថាប័ន និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត- ក្រុង ត្រូវផ្ញើរបាយការណ៍អំពីការអនុវត្តន៍ចំណូល- ចំណាយប្រចាំខែ មកនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិញ្ញវត្ថុអោយបានមុនថ្ងៃទី ១០ នៃខែបន្ទាប់ ។

- ក្នុងរយៈពេលចាប់ពីថ្ងៃទី ២០ ដល់ថ្ងៃទី ២៥ នៃខែចុងត្រីមាសនីមួយៗ នាយកដ្ឋានថវិកាត្រូវកោះប្រជុំពិភាក្សាជាមួយនាយកដ្ឋានពន្ធដារ ទីចាត់ការគយ និង រដ្ឋាករ រតនាគារជាតិ និង នាយកដ្ឋានពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីរៀបចំកម្មវិធីចំណូល-ចំណាយថវិការដ្ឋសំរាប់ត្រីមាសបន្ទាប់ ។ ផ្អែកលើមូលដ្ឋាននៃកម្មវិធីចំណូល-ចំណាយនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុធ្វើប្រកាសប្រគល់កម្មវិធីចំណូល-ចំណាយសំរាប់ត្រីមាសបន្ទាប់ តាមជំពូកថវិកាក្នុងកំរិតឥណទានអតិបរមាជូនដល់ក្រសួង-ស្ថាប័ននីមួយៗ និង មន្ទីរជំនាញខេត្ត-ក្រុងនីមួយៗ ដោយចម្លងជូននាយកដ្ឋានហិរញ្ញកិច្ច រតនាគារជាតិ និង អភិបាលខេត្ត-ក្រុង ។
- អាណាប័កដើមខ្សែ ឬ អាណាប័កតាមការប្រទានសិទ្ធ ត្រូវចេញអាណត្តិបើកប្រាក់នៅក្នុងរង្វង់នៃកម្មវិធីចំណាយប្រចាំត្រីមាសរបស់ខ្លួន ហើយនាយកដ្ឋានហិរញ្ញកិច្ច និង រតនាគារជាតិ ត្រូវចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ និង ត្រូវបើកជាសាច់ប្រាក់ តែនៅក្នុងកំរិតនៃកម្មវិធីប្រចាំត្រីមាសនេះតែប៉ុណ្ណោះ ។ ក្នុងករណីមានការចាំបាច់សុំបើកផ្តល់បន្ថែម សាម៉ីអង្គភាពត្រូវធ្វើសំណើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ហើយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងធ្វើប្រកាសផ្តល់កម្មវិធីបន្ថែម នៅក្នុងក្របខ័ណ្ឌឥណទានថវិកាដែលមិនទាន់បែងចែកនៅក្នុងកម្មវិធីចំណាយ ។
- រតនាគារត្រូវបញ្ជូនមកនាយកដ្ឋានថវិកា នូវរបាយការណ៍បេឡាប្រចាំថ្ងៃ របាយការណ៍ចំណូល-ចំណាយថវិកាប្រចាំខែ ព្រមទាំងសាលាកប័ត្របង់ប្រាក់ និង តារាងតុល្យភាពប្រចាំខែ ដើម្បីតាមដានបូកសរុបចំណូល ចំណាយថវិកាប្រចាំខែ ប្រចាំត្រីមាស ព្រមទាំងធ្វើការសន្និដ្ឋាន វាយតំលៃនូវសភាពការណ៍អនុវត្ត ធៀបនឹងខែមុន ត្រីមាសមុន នៃឆ្នាំនេះ និង ប្រៀបធៀបទៅនឹងខែ ត្រីមាសដូចគ្នានៃឆ្នាំមុន ។

## IV. នីតិវិធីចលនាឥណទានថវិកា

១៥- ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវប្រើប្រាស់ឥណទានថវិការបស់ខ្លួន ទៅតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដូចមានលំអិតនៅក្នុងសៀវភៅថវិកា ។ ចាប់ពីដើមត្រីមាសទី ២ ទៅក្នុងករណីដែលមានខ្ទង់ចំណាយថវិកាណាមួយមានឥណទានមិនគ្រប់គ្រាន់តែចាំបាច់ត្រូវចំណាយ ត្រូវធ្វើសំណើសុំនិយ័តភាពមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិនិត្យសំរេចជាមុនសិន ទើបលើកសំណើសុំខ្ទង់ចំណាយនោះបាន ។ បើក្រសួងស្ថាប័នមានសំណូមពរផ្តល់ឥណទានបន្ថែម ដូចជាចំណាយដំណើរការរដ្ឋបាល សំភារៈការជួសជុលតូច ការសាងសង់ និង ទិញសំភារៈ ។ល។ ទៅឱ្យមន្ទីរជំនាញរបស់ខ្លួននៅខេត្ត-ក្រុង នោះគឺត្រូវធ្វើឡើងដោយប្រកាសផ្ទេរឥណទានរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីឱ្យអភិបាលខេត្ត-ក្រុង (អាណាប័កតាមការប្រទានសិទ្ធិ) ដែលជាខ្សែទីង និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចតាមដានការប្រើប្រាស់ឥណទានថវិកាបន្ថែមទាំងនោះបាន ។

## V. វិធានការរក្សាគុណភាព និង ប្រសិទ្ធភាពថវិកា

១៦- នៅពេលដែលពិនិត្យឃើញថា ស្ថានភាពនៃការអនុវត្តន៍ថវិកានឹងមិនអាចសំរេចបានទៅតាមការគ្រោងទុក ដើម្បីរក្សាគុណភាព និង ប្រសិទ្ធភាពថវិកា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានវិធានការដូចខាងក្រោមៈ

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងធ្វើការត្រួតពិនិត្យលើការអនុវត្តន៍ថវិកាពាក់កណ្តាលឆ្នាំ ដើម្បីជាមូលដ្ឋានក្នុងការធ្វើថវិកាកែតំរូវក្នុងករណីចាំបាច់ ។
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបញ្ឈប់ និង មិនអនុញ្ញាតិអោយមានការបោះផ្សាយអាណត្តិតំកល់ទុកសំរាប់ចំណាយនៅឆ្នាំបន្ទាប់ទៀតទេ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ក្រសួង-ស្ថាប័ន និង ខេត្ត-ក្រុង ទាំងអស់នឹងរួមសហការក្នុងការអនុវត្តថវិកាឆ្នាំ ២០០៦ របស់យើង អោយសំរេចបានជោគជ័យតាមការគ្រោងទុក ដើម្បីបំរើអោយការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណរបស់សម្តេចនាយករដ្ឋមន្ត្រី និង ឆ្លើយតបទៅនឹងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី ៣ ជាពិសេសយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ចំលងជូន**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  (ដើម្បីជូនជ្រាបជាពិតមាន)
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់ខេត្ត- ក្រុង
  (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ